


## ជម្រើសរបស់ក្លាវែន

ក្លាវែន អែហ្វ រ៉ូប៊ីសុន បានរត់ប្រណាំងនៅក្នុងកីឡាអូឡាំពិករដូវក្ដៅឆ្នាំ ១៩៤៨ ហើយក្លាយជាគ្រូបង្វឹកអ្នករត់ប្រណាំងដ៏អស្ចារ្យនៅមហាវិទ្យាល័យ ។ កាលគាត់នៅក្មេង គាត់បានសន្យាថាគាត់នឹងគោរពតាមពាក្យសម្ដីនៃប្រាជ្ញាវាងវៃជានិច្ច ។ គាត់បានដឹងថា ការណ៍នេះពុំធ្វើឲ្យគាត់ឈ្នះគ្រប់ការប្រកួតរបស់គាត់ឡើយ ។ ប៉ុន្តែគាត់បានដឹងថាព្រះវរបិតាសួគ៌អាចជួយគាត់ ធ្វើឲ្យអស់ពីសមត្ថភាពរបស់ខ្លួន ពេលគាត់មានភាពស្អាតស្អំ និង សក្ដិសមព្រមទាំងមានសេចក្ដីជំនឿ ។

# ក្លាវែនប្រកួតនឹងកីឡាករជើងឯក

**ដោយ ឡូរី ហ្វូលើរ**
ទស្សនាវដ្ដីសាសនាចក្រ
ផ្អែកទៅលើដំណើររឿងពិត

ក្លាវែនបានក្រឡេកមើលទៅក្រៅកញ្ចក់ឡាន នៅពេលមើលឃើញកំពង់ផែ ។ ទូកអណ្ដែតលើទឹកនៅពីមុខផ្ទះ និង ហាងជាច្រើនដែលមានពណ៌ចម្រុះគ្នា ។ ខូភិនហាហ្គិន ដាណាម៉ាក ជាទីក្រុងមួយដ៏ស្រស់ស្អាតដែលមាន វាំង អគារស្ដឹមស្ដៃ និង សួនឧស្សាហ៍ស្អាតៗ ។ វាមិនដូចជាទីក្រុងរបស់ក្លាវែននៅក្នុងរដ្ឋ យូថាហ៍ ស.រ.អា.ឡើយ ។ ក្លាវែនអាចស្រមៃគិតពីផ្លូវដីហុយ ដែលជាផ្លូវគាត់រត់ប្រណាំងគ្នាកាលពីក្មេង ។ ឥឡូវនេះគាត់គឺជាសមាជិកម្នាក់នៅក្នុងក្រុមកីឡាកររត់ប្រណាំងសហរដ្ឋ ហើយថ្ងៃស្អែកគាត់នឹងជួបប្រកួតជាមួយនឹងអ្នករត់ប្រណាំងជនជាតិដាណឺម៉ាកដ៏ល្បីមួយរូបនៅក្នុងការប្រកួតដ៏សំខាន់មួយ ។

ឡានបានឈប់នៅសាលប្រជុំតូចមួយ ជាទីដែលការប្រជុំសាសនាចក្របានចាប់ផ្ដើម ។

កាលក្លាវែនបានចូលទៅសរសៀៗពីខាងក្រោយការប្រជុំ អ្នកផ្សព្វផ្សាយសាសនាម្នាក់អង្គុយនៅលើវេទិកាបានស្គាល់គាត់ ពីការអានអត្ថបទសារព័ត៌មានអំពីការប្រកួតពីម្សិលមិញ ។ ប្រធានសាខាបានស្នើសុំឲ្យក្លាវែនឡើងទៅលើវេទិកា ហើយនិយាយ ។

បន្ទាប់មកក្លាវែនប្រាប់អំពីមូលហេតុដែលគាត់មកព្រះវិហារ នោះមានក្មេងប្រុសម្នាក់បានក្រោកឡើង ហើយលើកដៃគាត់ ។ គាត់បានសួរ « តើអ្នកគិតថាអ្នកអាចយកឈ្នះលើជើងឯកដាណឺម៉ាកម្នាក់នោះដែរឬទេ ? »

ក្លាវែនទំនងដូចជាមិនដឹងថាត្រូវនិយាយអ្វីនោះទេ ។ កីឡាកររត់ប្រណាំង ដាណឺម៉ាក *បាន* រត់ក្នុងរយៈពេលតិច ក្នុងចម្ងាយជាច្រើនគីឡូម៉ែត្រនៅរដូវកាលប្រកួតនោះ ។

អ្នកផ្សព្វផ្សាយសាសនាម្នាក់នោះបានឆ្លើយពីមុនក្លាវែនបានឆ្លើយ « ពិតមែនហើយគាត់អាចធ្វើបាន ។ ដោយសារគាត់រស់នៅតាមពាក្យសម្ដីនៃប្រាជ្ញាវាងវៃ » ។ គាត់បានបើកគម្ពីររបស់គាត់ទៅ គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៩ ។ គាត់បានអានការសន្យាថា អស់អ្នកដែលគោរពតាមពាក្យសម្ដីនៃប្រាជ្ញាវាងវៃ « នឹងរត់ទៅឥតដែលហត់ ហើយនឹងដើរឥតដែលល្វើយឡើយ » (ខទី ២០) ។

តើក្លាវែនអាចនិយាយថាដូចម្ដេច ? *គាត់*បានដឹងថាពាក្យសម្ដីនៃប្រាជ្ញាវាងវៃគឺជាការពិត ។ ហើយកាលគាត់នៅពីក្មេងគាត់បានសន្យាថាគាត់នឹងគោរពតាមច្បាប់នេះជានិច្ច ។ ប៉ុន្តែការគោរពច្បាប់នេះតែមួយមុខគត់នោះ ពុំមែនមានន័យថាគាត់អាចឈ្នះលើការប្រកួតនេះឡើយ ។ ភាពជោគជ័យក៏តម្រូវឲ្យមានការអនុវត្ត និង មានជំនាញ ។ នៅពេលក្លាវែនបានចាកចេញពីការប្រជុំ គាត់បានគិតថា « មែនហើយគ្មាននរណាម្នាក់មកពីសាសនាចក្រ នឹងទៅមើលការប្រកួតនៅថ្ងៃស្អែកឡើយ » ។

នៅល្ងាចបន្ទាប់មក ពេលក្លាវែនកំពុងហាត់សមការប្រកួតរបស់ខ្លួន នោះគាត់បានមើល ហើយបានឃើញអ្នកផ្សព្វផ្សាយសាសនាពីរនាក់នៅក្នុងក្រុមយុវជនមួយដែលមានគ្នាប្រមាណ ១៧ នាក់ ។ ពួកគេ *បាន* មក !

នៅពេលពួកគេមកកាន់តែជិត មានអ្នកផ្សព្វផ្សាយបានខ្សឹបក្លាវែនថា « ប្រសិនបើអ្នកធ្លាប់រត់នៅក្នុងជីវិតរបស់អ្នក នោះអ្នកនឹងរត់បានកាន់តែល្អនាយប់នេះ » ។ ក្មេងប្រុសជាច្រើនពុំមែនជាសមាជិកសាសនាចក្រទេ ប៉ុន្តែបានមកជាមួយមិត្តភក្ដិរបស់ខ្លួន ដើម្បីមើលឃើញថា តើច្បាប់ពាក្យសម្ដីនៃប្រាជ្ញាវាងវៃនោះពិតឬទេ ។

ក្លាវែនព្រួយបារម្ភណាស់ ។ នៅក្នុងការប្រកួតនេះ សមត្ថភាពរបស់គាត់ប្រហែលជាមិនល្អគ្រប់គ្រាន់ឡើយ ។ ប៉ុន្តែគាត់កំពុងធ្វើតាមគោលការណ៍មួយនៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ។ គាត់ *ត្រូវតែ* ឈ្នះ ។ គាត់ពុំធ្លាប់អធិស្ឋានសុំឲ្យឈ្នះពីមុនឡើយ ប៉ុន្តែគាត់បានរកបន្ទប់ទំនេរមួយដើម្បីអធិស្ឋាន ។

គាត់បានអធិស្ឋានថា « ឱព្រះវរបិតា ដែលគង់នៅឋានសួគ៌ ខ្ញុំដឹងថាពាក្យសម្ដីនៃប្រាជ្ញាវាងវៃគឺពិត ហើយខ្ញុំមិនដែលរំលោភបំពានលើវាឡើយ ។ សូមប្រទានពរដល់ខ្ញុំនូវជោគជ័យនៅក្នុងការប្រកួតនេះ » ។ នៅពេលគាត់ដើរចេញទៅទីចាប់ផ្ដើម គាត់បានដឹងថាព្រះវរបិតាសួគ៌បានស្ដាប់ឮការអធិស្ឋានរបស់គាត់ ។ គាត់បានទុកចិត្តលើព្រះហឫទ័យរបស់ព្រះវរបិតាសួគ៌ ។

នាល្ងាចនោះមានភ្លៀងធ្លាក់ ហើយមានភក់ ។ នៅពេលក្លាវែនចាប់ផ្ដើមការប្រកួត វាហាក់បីដូចជាគាត់បានរត់អស់ជាច្រើនគីឡូម៉ែត្រមកហើយ ។ ល្បឿនរត់នោះលឿនណាស់ ហើយជើងឯង ដាណឺម៉ាកនោះបានរត់ទៅមុនគាត់ ។ ប៉ុន្តែនៅពេលក្លាវែនបានរត់បញ្ចប់ជុំទីបី ភ្លាមនោះគាត់មិននឿយហត់ទៀតឡើយ ។ គាត់បានចាប់ផ្ដើមរត់លឿនជាងមុន ហើយវាអត់ឈឺអ្វីឡើយ ។ រត់ទៅកាន់តែលឿនជាងមុន ហើយវាអត់ឈឺអ្វីឡើយ ។ គាត់បានរត់ហួសជើងឯក ដាណឺម៉ាក ហើយ *នៅតែ*រត់ទៅមុនយ៉ាងលឿន ។

នៅពេលក្លាវែនបានរត់មកដល់ជុំត្រឡប់វិញ គ្រូបង្វឹករបស់គាត់បានស្រែកថា « បន្ថយល្បឿន ! ប្អូននឹងមិនអាចរត់ដល់ទីផ្ដាច់ព្រ័តឡើយ ! » ។ ប៉ុន្តែក្លាវែនបានដឹងថា គាត់អាចបន្តរត់ទៀតបាន ។ ហើយនៅពេលគាត់បញ្ចប់ការប្រកួតរបស់ខ្លួន គាត់បានរត់លឿនជាងកីឡាករ ដាណឺម៉ាកនោះច្រើនជាង ៤៦ ម៉ែត្រ ! គាត់បានដឹងថាគាត់ឈ្នះដោយសារព្រះវរបិតាសួគ៌បានឆ្លើយតបការអធិស្ឋានរបស់គាត់ ហើយដោយសារពាក្យសម្ដីនៃប្រាជ្ញាវាងវៃគឺជាការពិត ។ ■

គំនូរដោយ ម៉ាត ស្មីធ